Australian Government
Department of Health and Aged Care

medicare

Khmer




# អំពីការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ និង Medicare

ការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ អនុញ្ញាតឱ្យអ្នកកាន់ប័ណ្ណ Medicare មានលទ្ធភាពទទួលបានការថែទាំសុខភាពដោយមិនគិតថ្លៃ ដែលធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការទទួលបានការថែទាំដែលអ្នកត្រូវការ នៅពេលដែលអ្នកត្រូវការវា។

រដ្ឋាភិបាលអូស្ត្រាលីកំពុងវិនិយោគលើ Medicare ដើម្បីធ្វើឱ្យប្រាកដថា ប្រជាជនអូស្ត្រាលីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានការថែទាំសុខភាព ការថែទាំបន្ទាន់ និងសេវាសុខភាពផ្លូវចិត្តដែលមានតម្លៃសមរម្យ។

## តើការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋគឺជាអ្វី?

ការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋមានន័យថា អ្នកមិនបង់ប្រាក់អ្វីទាំងអស់សម្រាប់សេវានោះទេ។ Medicare បង់ប្រាក់ឱ្យវេជ្ជបណ្ឌិតរបស់អ្នកដោយផ្ទាល់ ដោយផ្តល់មធ្យោបាយមួយដើម្បីទទួលបានការថែទាំសុខភាពដោយមិនចាំបាច់ចំណាយពីហោប៉ៅ។

## តើការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ ដំណើរការដូចម្តេចដែរ?

- **ជំហានទី 1៖ ទៅជួបវេជ្ជបណ្ឌិត ឬអ្នកជំនាញថែទាំសុខភាពរបស់អ្នក។** ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ អ្នកត្រូវយកប័ណ្ណ Medicare របស់អ្នកទៅកាន់ការណាត់ជួបរបស់អ្នក។
- **ជំហានទី 2៖** ដោយមានការអនុញ្ញាតពីអ្នក **វេជ្ជបណ្ឌិតរបស់អ្នកដាក់ស្នើការទាមទារដោយផ្ទាល់ទៅ Medicare** សម្រាប់សេវាដែលបានផ្តល់នោះ។
- **ជំហានទី 3៖ មិនចាំបាច់បង់ប្រាក់ទេ។** ដោយសារតែ Medicare បង់ប្រាក់ឱ្យវេជ្ជបណ្ឌិតរបស់អ្នកដោយផ្ទាល់ អ្នកមិនចាំបាច់បង់ប្រាក់អ្វីទាំងអស់នៅកន្លែងណាត់ជួបរបស់អ្នកទេ។

## តើសេវាអ្វីខ្លះដែលជាទូទៅត្រូវបានគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ?

- **ការទៅជួបវេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GP) និងសេវាសុខភាពតាមទូរសព្ទ៖** GP ជាច្រើនផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ ជាពិសេសសម្រាប់កុមារអាយុក្រោម 16 ឆ្នាំ អ្នកទទួលប្រាក់សោធននិវត្តន៍ ឬអ្នកដែលមានប័ណ្ណថែទាំសុខភាព។
- **សេវារោគសាស្ត្រ និងរោគវិនិច្ឆ័យ៖** ការធ្វើតេស្តឈាម និងកាំរស្មីអ៊ិចមួយចំនួនអាចនឹងត្រូវបានគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ អាស្រ័យលើអ្នកផ្តល់សេវានោះ។
- **ការធ្វើតេស្តភ្នែក៖** អ្នកឯកទេសពិនិត្យភ្នែកជាច្រើនផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋសម្រាប់ការធ្វើតេស្តភ្នែក។
- **ការទៅជួបពេទ្យធ្មេញ៖** ពេទ្យធ្មេញជាច្រើនផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋសម្រាប់ការពិនិត្យធ្មេញ សម្រាប់កុមារដែលមានសិទ្ធិទទួលក្រោម គម្រោងអត្ថប្រយោជន៍ថែទាំសុខភាពមាត់ធ្មេញសម្រាប់កុមារ (CDBS)។

## ចុះបើវេជ្ជបណ្ឌិតរបស់ខ្ញុំមិនផ្តល់ជូនសេវាគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ?

ប្រសិនបើវេជ្ជបណ្ឌិតរបស់អ្នកមិនផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋទេ អ្នកនៅតែអាចទាមទារអត្ថប្រយោជន៍ Medicare បន្ទាប់ពីអ្នកបង់ថ្លៃចំណាយពេញ។

- **ការបង់ប្រាក់ជាមុន៖** អ្នកបង់ថ្លៃចំណាយពេញ ហើយបន្ទាប់មកទាមទារប្រាក់មកវិញពី Medicare សម្រាប់សេវាកម្មនោះ។ សម្រាប់ព័ត៌មានបន្ថែមអំពីការទទួលបានអត្ថប្រយោជន៍ពី Medicare សូមចូលទៅកាន់គេហទំព័រ Services Australia។

## របៀបស្វែងរកអ្នកផ្តល់សេវាដែលគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋដែលនៅជិតអ្នក

- **ប្រើឧបករណ៍តាមអនឡាញ៖** ឧបករណ៍ស្វែងរក 'ស្វែងរកសេវាសុខភាព' អាចជួយអ្នកក្នុងការកំណត់ទីតាំង GP និងអ្នកឯកទេសនានាដែលផ្តល់ជូនការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ។
- **ទូរសព្ទជាមុន៖** មុនពេលការណាត់ជួបរបស់អ្នក សូមទូរសព្ទទៅគ្លីនិកដើម្បីសួរថាតើពួកគេគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ ហើយថាតើលក្ខខណ្ឌណាមួយអនុវត្ត ដូចជាអាយុ ឬស្ថានភាពប័ណ្ណថែទាំសុខភាពដែរឬទេ។



## ព័ត៌មានបន្ថែម

**ប្រជាជនអូស្ត្រាលីកាន់តែច្រើន ឥឡូវនេះអាចចូលប្រើសេវា GP ដោយមិនគិតថ្លៃតាមរយៈ ការលើកទឹកចិត្តថ្មីចំពោះការគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបដែល Medicare អាចជួយអ្នក សូមចូលទៅកាន់គេហទំព័រ medicare.gov.au/stronger**

ស្កេនដើម្បីស្វែងយល់បន្ថែម